**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ**

លេខ :..៣៤៤៤.......សផស

# សេចក្តីជូនដំណឹង

## ស្តីពី

## ឱកាសក្នុងការនាំចេញសត្វ និងផលិតផលសត្វទៅកាន់សាធារណរដ្ឋប្រជាមានិតចិន

វិស័យចិញ្ចឹមសត្វនៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មបានកើនឡើង៣៩% នៅឆ្នាំ២០២១ ដោយមានការវិនិយោគក្នុងទ្រង់ទ្រាយពីមធ្យមទៅធំជាពិសេសការចិញ្ចឹមជ្រូកដែលអាចផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងអាចនាំចេញទៅក្រៅប្រទេសបាន។

កិច្ចសហប្រតិបត្តិការជាដៃគូពាណិជ្ជកម្មរបស់កម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិនមានការរីកចម្រើនគួរឱ្យកត់សម្គាល់ស្របតាមតម្រូវការយ៉ាងខ្លាំងនៅសាធារណរដ្ឋប្រជាមានិតចិន។ ចំពោះផលិតផលកសិកម្ម កម្ពុជាបានចុះកិច្ចព្រមព្រៀង រៀបចំពិធីសារ និងបានដំណើរការនាំចេញនូវផលិតផលមួយចំនួនដូចជា អង្ករ ម្សៅដំឡូងមី ផ្លែចេកស្រស់ ផ្លែស្វាយស្រស់ ដំណាប់ស្វាយ ពោត និងមៀន។ ដើម្បីជំរុញការនាំចេញសត្វ និងផលិតផលសត្វទៅកាន់សាធារណរដ្ឋប្រជាមានិតចិននាពេលអនាគត សូមលោក លោកស្រី ជាវិនិយោគិនក្នុងវិស័យចិញ្ចឹមសត្វ និងផលិតផលសត្វ ដែលមានបំណងនាំចេញសត្វ និងផលិតផលសត្វដូចជា ជ្រូករស់ គោរស់ សាច់ជ្រូក សាច់គោ សាច់មាន់ ស្បែកគោ ស្បែកជ្រូក និងផលិតផលផ្សេងទៀត អាចធ្វើការស្នើសុំមកអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដោយបញ្ជាក់ពីប្រភេទសត្វ និងផលិតផលសត្វឱ្យបានច្បាស់លាស់ទៅតាមប្រភេទនីមួយៗ ដើម្បីឱ្យអគ្គនាយកដ្ឋានមានលទ្ធភាពរៀបចំបែបបទពាក់ព័ន្ធផ្សេងៗសុំការអនុញ្ញាតពីភាគីចិន ដើម្បីចុះមកត្រួតពិនិត្យ និងវាយតម្លៃហានិភ័យ និងឈានទៅរកការរៀបចំពិធីសារអនាម័យ និងកិច្ចព្រមព្រៀងក្នុងការនាំចេញ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រី ជាវិនិយោគិនក្នុងវិស័យចិញ្ចឹមសត្វ និងផលិតផលសត្វ ដែលមានបំណងនាំចេញនូវសត្វ និងផលិតផលសត្វ សូមធ្វើការស្នើសុំមកអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ថ្ងៃសុក្រ ១៣ រោចខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**

**អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ**

**តាន់ ផាន់ណារ៉ា**

**ចម្លងជូន៖**

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  "ដើម្បីជូនជ្រាប"
- គ្រប់នាយកដ្ឋាន និងវិទ្យាស្ថានក្រោមឱវាទអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ភូមិទ្រា ផ្លូវលេខ ៣៧១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កម្ពុជា
Trea Village, Str. 371, Sangkat Steung Mean Chey, Khan Mean Chey, Phnom Penh Cambodia
ទូរស័ព្ទលេខ : (៨៥៥) ២៣ ៨៨៣ ៧៤៦/៨៨៤ ១៤៨ ទូរសារ: (៨៥៥) ២៣ ៨៨៣ ៧៤៦/៨៨៤ ១៤៨
Tel.: (855) 23 883 746/884 148 Fax.: (855) 23 883 746/884 148